**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដី ចំនួន ០៤ទីតាំង មានផ្ទៃដីសរុបទំហំ ៧១.០៦៩ ម$^2$ (ចិតសិបមួយពាន់សូន្យហុកសិបប្រាំបួន ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើ

អនុបយោគ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងនោះរួមមាន៖

- ទីតាំងទី១. មានផ្ទៃដី ទំហំ ២៩.៣៨៤ម² (ម្ភៃប្រាំបួនពាន់ បីរយសែសិបប្រាំបី ម៉ែត្រក្រឡា) ស្ថិតក្នុងភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី២. មានផ្ទៃដី ទំហំ ១៣.៦៧២ ម² (ដប់បីពាន់ ប្រាំមួយរយចិតសិបពីរ ម៉ែត្រក្រឡា) ស្ថិតក្នុងភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៣. មានផ្ទៃដី ទំហំ ២៥.៩៤៤ម² (ម្ភៃប្រាំពាន់ ប្រាំបួនរយសែសិបបួន ម៉ែត្រក្រឡា) ស្ថិតក្នុងភូមិសំរោងត្បូង សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៤. មានផ្ទៃដី ទំហំ ២.១០៥ ម² (ពីរពាន់ មួយរយដប់ប្រាំ ម៉ែត្រក្រឡា) ស្ថិតក្នុងភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ)។

**មាត្រា ២**: ត្រូវបានធ្វើប្រទានកម្មផ្ទៃដី ចំនួន ០៤ ទីតាំង សរុបទំហំ ៧១.០៦៩ ម² (ចិតសិបមួយពាន់ សូន្យហុកសិបប្រាំបួន ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់សំរោង និងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូនលោកស្រី សុក ស្រីពៅ, អេង ស៊ីឆេង និង លោកស្រី វ៉ាន់ ធីតា ដោយពន្ធ និងអាករផ្សេងៗ ជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣**: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍..៥រោច. ខែ..មាឃ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..២៦... ខែ.មករា.... ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៤*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 482419.980 | 1287644.396 | 6 | 482362.686 | 1287632.127 |
| 2 | 482448.461 | 1287477.821 | 7 | 482371.892 | 1287752.890 |
| 3 | 482416.311 | 1287445.848 | 8 | 482391.891 | 1288015.212 |
| 4 | 482399.842 | 1287503.057 | 9 | 482447.146 | 1287909.668 |
| 5 | 482372.262 | 1287598.863 | 10 | 482431.608 | 1287684.880 |

**ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 482526.033 | 1288149.799 | 6 | 482391.891 | 1288015.212 |
| 2 | 482475.285 | 1288126.036 | 7 | 482399.850 | 1288119.616 |
| 3 | 482460.998 | 1288092.698 | 8 | 482442.717 | 1288156.696 |
| 4 | 482449.885 | 1288019.144 | 9 | 482506.921 | 1288186.306 |
| 5 | 482447.146 | 1287909.668 | | | |

**ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 482506.921 | 1288186.306 | 11 | 482825.144 | 1288336.223 |
| 2 | 482616.548 | 1288236.864 | 12 | 482865.357 | 1288359.010 |
| 3 | 482621.432 | 1288238.812 | 13 | 482917.612 | 1288404.651 |
| 4 | 482633.108 | 1288243.469 | 14 | 482979.288 | 1288472.444 |
| 5 | 482696.691 | 1288268.826 | 15 | 482998.841 | 1288430.022 |
| 6 | 482738.303 | 1288289.349 | 16 | 482995.171 | 1288410.853 |
| 7 | 482744.631 | 1288292.471 | 17 | 482955.884 | 1288373.475 |
| 8 | 482758.088 | 1288299.108 | 18 | 482926.780 | 1288341.063 |
| 9 | 482770.106 | 1288305.035 | 19 | 482847.022 | 1288288.589 |
| 10 | 482816.432 | 1288331.286 | 20 | 482526.033 | 1288149.799 |

**ឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 483361.630 | 1288569.795 | 7 | 483232.146 | 1288553.957 |
| 2 | 483361.918 | 1288553.046 | 8 | 483229.107 | 1288564.417 |
| 3 | 483349.154 | 1288559.001 | 9 | 483227.562 | 1288569.733 |
| 4 | 483341.004 | 1288561.012 | 10 | 483278.250 | 1288578.622 |
| 5 | 483285.442 | 1288562.811 | 11 | 483358.465 | 1288575.318 |
| 6 | 483262.370 | 1288560.377 | | | |

